THE SCHOOL DISTRICT OF PHILADELPHIA

# ព្រឹត្តិប័ត្រព័ត៌មានអំពីការអំពាវនាវចាត់ចំណាត់ការ

FUND OUR SCHOOLS

## វិបត្តិនៅខាងមុខ

វិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីជំងឺរាតត្បាត COVID-19 កំពុងជះឥទ្ធិពលយ៉ាងខ្លាំងដល់មណ្ឌលសិក្សា Philadelphia (SDP)។ យើងសូមកោតសរសើរចំពោះចំណាត់ការនាពេលថ្មីៗនេះរបស់រដ្ឋ Pennsylvania ក្នុងការអនុម័តថវិកាដែលរក្សាកម្រិតថវិកាបច្ចុប្បន្នសម្រាប់វិស័យអប់រំសាធារណៈ ប៉ុន្តែវាមិនគ្រប់គ្រាន់ទេ។ មណ្ឌលសិក្សានៅតែកំពុងប្រឈមមុខនឹងវិបត្តិហិរញ្ញវត្ថុដោយសារតែការខាតបង់ប្រាក់ចំណូលក្នុងស្រុក និងការចំណាយថ្មីដែលទាក់ទងនឹងជំងឺ COVID-19។ ត្រូវការថវិកាបន្ថែមទៀតដើម្បីការពារការវិនិយោគដែលយើងបានបណ្តាក់ទុនក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយនេះ ដើម្បីបង្កើនធនធាន និងសេវាកម្មគាំទ្រដល់សិស្សរបស់យើង។

ជាភ័ព្វសំណាង ច្បាប់ HEROES នឹងជួយដោះស្រាយបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុរបស់យើងជាច្រើនដែលបណ្តាលមកពីជំងឺ COVID-19។ ប្រសិនបើព្រឹទ្ធសភាសហរដ្ឋអាមេរិកអនុម័តច្បាប់ HEROES ច្បាប់នេះនឹងផ្តល់ថវិកាចំនួន 60 ពាន់លានដុល្លារបន្ថែមទៀតសម្រាប់មូលនិធិសង្គ្រោះបន្ទាន់សម្រាប់សាលារៀនក្នុងប្រទេសរបស់យើងរួមទាំងថវិកាចំនួនជាង 450 លានដុល្លារសម្រាប់មណ្ឌលសិក្សារបស់យើងដើម្បីធានាថា សិស្ស និងបុគ្គលិកមានសុខភាពល្អ សុវត្ថិភាព និងអាចរៀននៅពេលសាលារៀនចាប់ផ្តើមជាថ្មីម្តងទៀតនៅរដូវស្លឹកឈើជ្រុះ។

## អ្វីដែលយើងត្រូវការពីអ្នកតំណាងរាស្រ្តឥឡូវនេះ

ដើម្បីជួយមណ្ឌលសិក្សារក្សាដំណើរការសាលារៀន និងទិញសម្ភារផ្គត់ផ្គង់ដែលត្រូវការខ្លាំង ដើម្បីគាំទ្រដល់សុវត្ថិភាព និងសុខុមាលភាពរបស់សហគមន៍មណ្ឌលសិក្សាទាំងមូល យើងត្រូវការឲ្យព្រឹទ្ធសភាសហរដ្ឋអាមេរិកអនុម័តច្បាប់ HEROES។

### បន្តធ្វើឱ្យសិស្ស និងបុគ្គលិកមានសុខភាពល្អ សុវត្ថិភាព និងត្រៀមរៀន។

ជំងឺរាតត្បាត COVID-19  មានឥទ្ធិពលយ៉ាងខ្លាំងទៅលើថវិការបស់មណ្ឌលសិក្សា។ ព្រឹទ្ធសភាសហរដ្ឋអាមេរិកកំពុងពិចារណាលើច្បាប់ដែលនឹងផ្តល់ជំនួយសង្គ្រោះដែលត្រូវការចាំបាច់ខ្លាំង និងធានាថាមានថវិកា ដើម្បីគាំទ្រគោលការណ៍ណែនាំអំពីការរក្សាគម្លាតសុវត្ថិភាពក្នុងសង្គម និងរក្សាសុខភាពតាមរយៈការផ្តល់បទពិសោធន៍អប់រំយ៉ាងតឹងរ៉ឹងដល់សិស្ស។

**ស្នើសុំ៖ អនុម័តច្បាប់ HEROES។**
**ផ្តល់ជូនសាលាក្នុងប្រទេសរបស់យើងនូវទឹកប្រាក់ 60 ពាន់លានដុល្លារ ដើម្បីបន្តធ្វើឲ្យសិស្ស និងបុគ្គលិកមានសុខភាពល្អ មានសុវត្ថិភាព និងត្រៀមរៀន។**



## តើអ្នកអាចចាត់វិធានការយ៉ាងដូចម្តេច!

**ចាប់ពីថ្ងៃទី 25 ខែមិថុនា  រៀងរាល់ថ្ងៃព្រហស្បតិ៍ គឺជាទិវាតស៊ូមតិដើម្បីការអប់រំសាធារណៈនៅទីក្រុង Philadelphia។** តោះយើងបញ្ចេញសំឡេងមតិរបស់យើងឲ្យឮនៅរដ្ឋ Washington D.C. រាល់ថ្ងៃព្រហស្បតិ៍រហូតទាល់តែច្បាប់ HEROS ត្រូវបានអនុម័ត។

**សូមហៅទូរស័ព្ទ និងផ្ញើសារទៅសមា**ជិកព្រឹទ្ធសភា Toomey និងសមាជិកព្រឹទ្ធសភា Casey ដើម្បីជម្រាបពួកគាត់ឲ្យដឹងថាអ្នកកំពុងពឹងពួកគាត់ ***ផ្តល់មូលនិធិដល់សាលារៀនរបស់យើង!***

**សូមចូលរួមយុទ្ធនាការតាមបណ្តាញទំនាក់ទំនងសង្គមរបស់យើង**ដោយប្រើ #fundourschools ដើម្បីស្នើសុំសមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិករបស់យើងនៅរដ្ឋ Washington D.C. ផ្តល់ ***Fund Our Schools!***

**សូមចូលមើលគេហទំព័រ៖ philasd.org/fundourschools** សម្រាប់ព័ត៌មានទាក់ទងមន្ត្រីជាប់ឆ្នោតរដ្ឋទាំងអស់ គំរូអត្ថបទ និងលិខិត ហើយនិងព័ត៌មានលម្អិតបន្ថែមទៀតអំពីវិធីតស៊ូមតិនៅរដ្ឋធានី Harrisburg ដើម្បីផ្តល់ ***Fund Our Schools!***

ចំពោះព័ត៌មានបន្ថែម សូមចូលមើលគេហទំព័រ **philasd.org/fundourschools**